# ប្រាសាទថ្មបុី

ប្រាសាទថ្មបុី មានទីតាំងស្ថិតនៅភូមិជ្រលង ឃុំដារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ក្បែរជើងភ្នំទូកមាស មានចម្ងាយប្រមាណ២០គ.ម.ពីទីរួមស្រុកកំពង់លែង និងចម្ងាយ ៥០០ម៉ែត្រខាងលិចភូមិជ្រលង។ កាលពីរវាងដើមសតវត្សរ៍ទី២០ ក្នុងពេលដែលអ្នកស្រាវជ្រាវមកពីតំបន់អឺរ៉ុបមកសិក្សាស្រាវជ្រាវអំពីប្រាសាទខ្មែរ គេពុំបានសិក្សានិងចុះបញ្ជីប្រាសាទនេះឡើយ។ ជាពិសេសគឺនៅក្នុងសៀវភៅបញ្ជីរបស់លោក Etienne Aymonier និងលោក Lunet De Lajonquire ពុំបានចុះក្នុងបញ្ជីប្រាសាទនេះឡើយ។ ពោល គឺទើបតែនៅរវាងដើមសតវត្សរ៍ទី២១នេះប៉ុណ្ណោះ ដែលមានអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិចុះសិក្សាអំពីប្រាសាទនេះ។

ឈ្មោះថា "ថ្មបុី" គឺជាឈ្មោះដែលអ្នកស្រុករស់នៅក្នុងក្បែរប្រាសាទហៅតំបន់នេះ ហើយអ្នកស្រាវជ្រាវសម័យក្រោយក៏ហៅតាមអ្នកស្រុកថាដូច្នោះដែរ។ អ្នកស្រុកចងចាំរឿងព្រេងមួយដែលតំណាលទាក់ទងនឹងឈ្មោះប្រាសាទនេះ។ រឿងនោះនិទានថា "*កាលពីព្រេងនាយ មានបុរសម្នាក់ មានប្រពន្ធពីរនាក់រស់នៅក្នុងប្រាសាទនេះ។ ក្រោយមក បុរសនោះក៏កើតជំងឺឃ្លង់។ ដោយមានកក្តីភាពស្មោះស្ម័គ្រ នារីទាំងពីរនាក់ជាប្រពន្ធពុំបានបោះបង់បុរសជាប្តីដែលកើតឃ្លង់នោះឡើយ ពោលគឺនាងទាំងពីរនៅមើលថែទាំ ប្រេបាច់ដៃជើង ផ្ញួតទឹកឲ្យប្តីជាប្រចាំ។ ក្រោយមកដោយមើលឃើញពីកក្តីភាពនេះហើយ ទើបគេហៅនាងទាំងពីរនាក់ថា នាងថ្មបុី ហើយក៏ជាប់ឈ្មោះថា "ថ្មបុី" នៅប្រាសាទនេះរហូតមក*"។ បន្ទាប់ពីបានស្តាប់រឿងព្រេងនិទានរបស់អ្នកស្រុករួចមក យើងយល់ថារឿងនេះទំនងកើតចេញនៅពេលដែលអ្នកស្រុកបានឃើញផ្តែរមួយនៅលើទ្វារប្រាសាទ។ ផ្តែរនេះមានចម្លាក់សាច់រឿងព្រះវិស្ណុផ្ទុំបង្កើតលោក ហើយសព្វថ្ងៃផ្តែរនេះគេយកទៅរក្សាទុកនៅសារមន្ទីរជាតិភ្នំពេញ (រូបទី១)។ គម្ពីរព្រហ្មញ្ញសាសនានិទានថា "*នៅពេលមួយដែលលោកធាតុទាំងមូលជួបគ្រោះទុរភិក្ស ព្រះឥសូរដែលជាអាទិទេពកំពូលទ្រង់បានបំផ្លាញលោកចាស់បង្កើតលោកមួយថ្មី។ នៅពេលទ្រង់បំផ្លាញរួចរាល់ សភាវៈមានជីវិតនៅលើផែនដីបានបាត់បង់ទាំងអស់ ហើយពេលនោះព្រះវិស្ណុបានផ្ទុំនៅលើនាគអនន្តនៅកណ្តាលមហាសាគររង់ចាំបង្កើតលោកថ្មី។ រូបភាពនៃការផ្ទុំបង្កើតលោកយើងឃើញមានរូបទេពស្រីពីរនាក់នៅចុងព្រះបាទទ្រង់ គឺព្រះនាងលក្ស្មី និងព្រះនាងភូមិ ដែលជាព្រះមហេសីរបស់ព្រះវិស្ណុ។ ពេលនោះមានផ្កាឈូកមួយកើតចេញពីផ្ចិតរបស់ព្រះអង្គ ដែលនៅពីលើផ្កាឈូកមានព្រះព្រហ្មអង្គុយពីលើ។ ពេលនោះ*

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

ហើយដែលព្រះព្រហ្មត្រូវមានតួនាទីបន្តពីវិស្ណុដើម្បីបង្កើតសភាវៈមានជីវិតនានានៅលើផែនដី" ។[១] ដូច្នេះ ឈ្មោះថា "ថ្នមប្តី" គឺមានប្រភពមកពីអ្នកស្រុកឃើញរូបចម្លាក់ព្រះនាងលក្ស្មី និងភូមិនៅចុងព្រះបាទព្រះវិស្ណុ ដែលមើលទៅក្នុងកាយវិការដូចមើលថែស្វាមី ទើបគេហៅប្រាសាទនេះថា "ថ្នមប្តី"។ ជាទូទៅ ឈ្មោះប្រាសាទនៅស្រុកខ្មែរដែលមានចម្លាក់រូបព្រះវិស្ណុផ្ទុំគេតែងហៅឈ្មោះខុសៗគ្នា ឧទាហរណ៍ នៅសំបូរព្រៃគុក គេហៅថា "ប្រាសាទស្រីគ្រប់លក្ខណ៍" [២] និងនៅសៀមរាបមានប្រាសាទមួយគេហៅថា "ស្លាប់ប្តី" [៣]ដ្បិតគេមើលទៅឃើញព្រះវិស្ណុផ្ទុំដូចជាមនុស្សស្លាប់ដូច្នោះ។

ប្រាសាទថ្នមប្តី កសាងឡើងអំពីឥដ្ឋ មានតួប៉មចំនួនពីររត់ជួរពីជើងទៅត្បូង បែរមុខទៅទិសខាងកើត និងទំនងមានកំពែងធ្វើពីឥដ្ឋព័ទ្ធជុំវិញ (រូបទី២-៣)។ តួប៉មទាំងពីរមានរាងបួនជ្រុងស្មើដែលមានប្រវែងប្រមាណ ៤ម៉ែត្រក្នុងមួយជ្រុង ហើយតួប៉មទាំងពីរមានទំហំប៉ុនគ្នា ឬខាងត្បូងធំជាងតិចតួច (យើងពិបាកសន្និដ្ឋានដោយសារភាពទ្រុឌទ្រោម)។ តួប៉មខាងត្បូងនៅមានរូបរាងល្អប្រសើរច្រើន (រូបទី៤) រីឯតួប៉មខាងជើងបានបាក់រលំជញ្ជាំងផ្នែកខាងលិចអស់ទៅហើយ (រូបទី៥)។ ស៊ុមទ្វារប្រាសាទថ្នមប្តី យើងឃើញមានទម្រង់សិល្បៈដូចស៊ុមទ្វារនៅប្រាសាទភ្នំពណ្ណរាយដែលស្ថិតនៅមិនឆ្ងាយពីប្រាសាទថ្នមប្តី ពោល គឺផ្នែកខាងមុខនៃថ្មមេទ្វារគេដាប់ចេញជារូបរាងសសរមានរាងបួនជ្រុងស្មើដែលមានប្រវែងមួយជ្រុង២០ស.ម. (រូបទី៦)។

កាលពីមុនទីតាំងនេះធ្លាប់រកឃើញផ្តែរទ្វារចំនួនពីរផ្ទាំង។ ផ្ទាំងទី១ រក្សាទុកនៅសារមន្ទីរជាតិភ្នំពេញ ដែលមានចម្លាក់ព្រះវិស្ណុផ្ទុំបង្កើតលោកដូចរៀបរាប់ខាងលើ។ ចំណែក ផ្ទាំងទី២ រក្សាទុកនៅសារមន្ទីរខេត្តកំពង់ឆ្នាំង ដែលមានចម្លាក់ព្រះឥន្ទ្រគង់នៅលើដំរីឰរ៉ាវ័តនៅចំកណ្តាល (រូបទី៧)។ ផ្តែរទ្វារទាំងពីរផ្ទាំងនេះ មានទម្រង់ជាសិល្បៈរចនាបថប្រែរូប នាស.វ.ទី១០ ពោល គឺដូចផ្តែរទ្វារប្រាសាទភ្នំពណ្ណរាយដែលនៅមិនឆ្ងាយពីគ្នាដែរ។ ក្រៅពីនេះ យើងឃើញនៅសេសសល់ជើងទម្របដិមា (រូបទី៨) និងសសរពេជ្ររាងប្រាំបីជ្រុងមួយដើមដែរ (រូបទី៩)។ ប្រាសាទថ្នមប្តីពុំមានសេសសល់ផ្ទាំងសិលាចារឹកឲ្យយើងសិក្សានោះទេ។ ប៉ុន្តែ យោងតាមរយៈរូបរាងសំណង់និងក្បាច់លម្អសិល្បៈដូចជា ផ្តែរ សសរពេជ្រ និងជើងទម្របដិមា យើងអាចសន្និដ្ឋានបានថា ប្រាសាទថ្នមប្តីទំនងសាងឡើងនៅស.វ.ទី១០ រចនាបថប្រែរូប ក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន។ ប្រាសាទនេះទំនងជាសំណង់ព្រហ្មញ្ញសាសនាឧទ្ទិសដល់ព្រះវិស្ណុ ដ្បិតគេតែងសង្កេតឃើញថា ប្រាសាទមាន

---

[១] Roveda 2005: 55; Bénisti 1965: 91-117.

[២] Bénisti 1974: 132-133.

[៣] Lajonquière 1902: 278.

*តួប៉មពីរដូច្នេះ ច្រើនតែជាប្រាសាទឧទ្ទិសដល់ព្រះវិស្ណុ។ ជាក់ស្តែង មានដូចជា ប្រាសាទគោកចក ប្រាសាទព្រះឥន្ទ្រកោសីយ៍ ប្រាសាទនាងខ្មៅ ប្រាសាទរកាជន្ទឹង ជាតឹកតាងស្រាប់។*[២]

## ឯកសារយោង


*សុខ កែវសុវណ្ណារ៉ា*

២០២០, *ទស្សនៈថ្មីលើប្រាសាទព្រះវិស្ណុ*, សៀមរាប

**Aymonier, Etienne**

1900, *Le Cambodge: Le Royaum Actuel*. Paris. Ernest Leroux.

**Bénisti, Mireille**

- 1965, “Représentations Khmères de Viṣṇu couché”, *Art Asiatiques*, Tome 11, Paris
- 1974, Recherches sur le premier art khmer, VI. Linteaux inéits et linteaux méconnus, *Art Asiatique*, Tome 30, Paris

**Lunet De Lajonquière**

1902, *Inventaire descriptive des monuments du Cambodge*, Tome I, Paris

**Roveda, Victorio**

2005, “*Image of the gods*”, Bangkok




*រូបទី១៖ ផ្តែរទ្វារចម្លាក់ព្រះវិស្ណុផ្ទុំនៅប្រាសាទថ្នមប្តី (សព្វថ្ងៃនៅសារមន្ទីរជាតិភ្នំពេញ)*

[២] *សុខ កែវសុវណ្ណារ៉ា ២០២០។*

*អត្ថបទដោយ៖ ម៉ង់ វ៉ាលី*



រូបទី២៖ ប្រាសាទថ្មបី្ត (មើលពីមុខខាងកើត)



រូបទី៣៖ ប្រាសាទថ្មបី្ត (មើលពីមុខនិរតី)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបទី៤៖ តួប៉មខាងត្បូង (មើលពីមុខខាងកើត)



រូបទី៥៖ តួប៉មខាងជើង (មើលពីមុខខាងលិច)



រូបទី៦៖ ស៊ុមទ្វារប្រាសាទថ្មបុីក

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបទី៧៖ ផ្តែរទ្វារប្រាសាទថ្មបី្ត រក្សាទុកនៅសារមន្ទីរខេត្តកំពង់ឆ្នាំង (ប្រភព៖ សន ចាន់ធឿន)





រូបទី៨-៩៖ ជើងទម្របដិមា និងសសរពេជ្រ ប្រាសាទថ្មបី្ត